# ពាក្យផ្ដើម

ទស្សនិកជនដែលស្គាល់នូវកតិកានៃការលេងកីឡា ពេលទស្សនាល្បែងកីឡា គេរមែងទទួលស្គាល់នូវការសប្បាយរីករាយជាងអ្នកដែលមិនស្គាល់យល់ច្បាស់នូវកតិកានៃកីឡានោះ យ៉ាងណាមិញអ្នកដែលបានយល់ដឹងអំពីរឿងជីវិត គឺរឿងពិតរបស់ជីវិតអ្នកនោះក៏រមែងរស់នៅមានប្រៀប ជាងអ្នកដែលមិនបានយល់អំពីរឿងជីវិតក៏ដូច្នោះដែរ ។

ព្រះធម៌គឺជាការចោទ និង ដោះស្រាយនូវរាល់បញ្ហាជីវិតតាមហេតុផលពិតគំនិតយុត្តិធម៌ ឱ្យតែជីវិតនោះព្រមអោយព្រះធម៌ជួយដោះស្រាយ ផ្ទុយមកវិញ អ្នកដែលមិនត្រូវការព្រះធម៌ ឬប្រាសចាកធម៌ សូម្បីកំពុងមានជីវិតរស់នៅ ក៏ទុកដូចជាមនុស្សស្លាប់ទៅហើយ ព្រោះខ្វះខាតសេចក្ដីសុខ សេចក្ដីចំរើន និង គុណសម្បត្តិ អាចនិយាយបានថាអ្នកនោះជាមនុស្សស្លាប់ទាំងរស់ ស្អុយទាំងស្រស់ ។

កូនសៀវភៅដែលមានឈ្មោះថា "**ជីវិតពិតជាគ្រូខាងធម៌**" នេះ ថ្វីបើមានទំព័រមិនសូវច្រើន តែខ្ញុំសង្ឃឹមថាកូនសៀវ-

ភៅនេះនឹងក្លាយជាកល្យាណមិត្តដ៏ប្រសើររបស់លោកអ្នកអានទាំងអស់ ។ សូមអោយសេចក្តីចំរើនផ្នែកស្មារតីកើតមានដល់ញាតិញោម បងប្អូនប្រុសស្រី គ្រប់វ័យ គ្រប់ភេទ គ្រប់ស្រទាប់វណ្ណៈ ដែលកំពុងកាន់កូនសៀវភៅនេះអានឱ្យបានគ្រប់ៗគ្នា ។

សូមអោយអក្សរ សិល្បៈបវរ ជាមរតិកជាតិ
បានរីកចំរើន កកើនលូតលាត កុំអោយឃ្លាងឃ្លាត
រោយរាយអន្តរាយ ។

សូមឱ្យបិសាច ចិត្តបាបកំណាច រលាយខ្ចាត់ខ្ចាយ
អំពីសន្តាន សព្វសត្វទាំងឡាយ បានសុខសប្បាយ
ផុតក្តីសៅហ្មង ។

ពោធិ៍សាត់ ថ្ងៃ សុក្រ ១៥កើត ខែ ស្រាពណ៍ ឆ្នាំមមី ព.ស ២៥៤៦

ភិក្ខុវជិរប្បញ្ញោ សាន-សុជា

# មាតិការអត្ថបទ

| ល.រ | ឈ្មោះធម៌ | ទំព័រ |
|---|---|---|
| ១ | ជីវិតពិតជាត្រូវការធម៌ | ០១ |
| ២ | សីលធម៌ ឬសីល៥ | ០៥ |
| ៣ | សីលទី ១ (មិនសម្លាប់សត្វ) | ០៧ |
| ៤ | សីលទី ២ (មិនលួចទ្រព្យគេ) | ១០ |
| ៥ | សីលទី ៣ (មិនប្រព្រឹត្តខុសក្នុងកាម) | ១៦ |
| ៦ | សីលទី ៤ (មិននិយាយកុហក) | ១៩ |
| ៧ | សីលទី ៥ (មិនផឹកទឹកស្រវឹង) | ២២ |
| ៨ | ឈ្មោះអ្នកអត់សីល (កំណាព្យ) | ២៦ |
| ៩ | សីលប្រាំជាផ្លូវការពារអបាយ (កំណាព្យ) | ២៨ |
| ១០ | ឈ្មោះសប្បុរសជនអ្នកបរិច្ចាកប្រាក់បោះពុម្ព | ៣០ |

# ជីវិតពិតជាត្រូវការធម៌

រឿងរបស់ជីវិតគឺជារឿងស្មុគ្រស្មាញបណ្ដាញទុក្ខ ច្របូកច្របល់ ក្រហល់ក្រហាយ ខ្វល់ខ្វាយ រកកលនឹងដោះស្រាយឱ្យឆ្ងាយពីទុក្ខមិនងាយបាន គ្រប់ប្រាណតាំងតែពីកើតមករហូតដល់ចាស់សក់ស្កូវក៏នៅតែមិនទាន់ចប់រឿងដែលត្រូវដោះស្រាយដដែល មិនថាអតីតៈ បច្ចុប្បន្ន ឬអនាគតកាលឡើយ ឱ្យតែកើតមកហើយត្រូវតែមានបញ្ហាដែលត្រូវដោះស្រាយជានិច្ច ។ ព្រោះតែជីវិតពោរពេញទៅដោយភាពស្មុគ្រស្មាញយ៉ាងនេះហើយ ទើបបណ្ដាលអោយមានបុគ្គលដ៏អស្ចារ្យម្នាក់ ខំព្យាយាមបំពេញបារមីអស់រយៈកាល ៤អសង្ខេយ្យ កំរៃ១សែនកប្ប ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ហើយបានប្រកាសប្រាប់នូវរូបមន្តដ៏វិសេសបំផុត មានចំនួន ៨៤.000ព្រះធម្មក្ខន្ធ ដែលហៅថាព្រះធម៌ ឬ ព្រះពុទ្ធសាសនានេះឯង ។

ជនមួយចំនួនដែលមិនស្គាល់ មិនយល់ច្បាស់នូវតម្លៃរបស់ព្រះពុទ្ធសាសនា ព្រោះគេមិនបានសិក្សា ឬមិនបានពិចារណាឱ្យចេះយល់ស្គាល់ច្បាស់នូវព្រះពុទ្ធសាសនាថាមានអ្វីខ្លះ ? ក្នុងនោះគេមានគំនិតផ្ទុយនឹងជីដូនជីតាយើង ចិត្តគំនិតរបស់គេកំពុងរសាត់

អណ្ដែតសែតអញ្ចង់ វិលវល់ក្នុងរឿងដទៃទៀតច្រើនសែនច្រើន គេបែរជាឃើញការកាន់សាសនា ប្រព្រឹត្តធម៌អាថ៌ ចរិយាប្រសើរ ថាជាអំពើលាសម័យ ការទៅវត្តស្ដាប់ធម៌ ធ្វើបុណ្យទានវាជារឿង គួរអោយអៀនខ្មាស ឃើញថាជាការប្រសើរ ស៊ូនៅតាមរោង ភាពយន្ត ឬ រាត្រីសមោសរ ដែលមានពួកនារីស្អាត១ ល្អ១ តុបតែង តួយ៉ាងស្រស់ឆើតឆាយប្រកបដោយសូរសព្ទតន្ត្រី និង ចំរៀង ប្រលោមកាម ព្រមទាំងសូរសព្ទនៃកែវស្រាយ៉ាងគួរអោយភ្លើត ភ្លើន ស្រើបស្រាល បើមានអ្នកណាទៅនិយាយធម៌អាថ៌-សាសនា ក្នុងទីនោះ គេទាំងនោះ ក៏មិនត្រូវការស្ដាប់ ឯអ្នកនិយាយអាចនឹង ត្រូវគេចំអកឡកឡឺយពេបជ្រាយអោយថា ខួរក្បាលបុរាណខ្លះ ថា ជឿឆោត១ខ្លះ ព្រមទាំងដៀលត្មះធម៌អាថ៌ឬពុទ្ធសាសនាដោយ ប្រការផ្សេង១ សំដែងសំដីថា ខ្លួនប្រសើរជាងព្រះពុទ្ធសាសនាទៅ ទៀត ។ ការនិយាយយ៉ាងនេះ ក៏មិនបានម៉ៅសំដៅសេចក្ដីថា គ្រប់ មនុស្សទាំងអស់សុទ្ធតែមានលក្ខណៈយ៉ាងនេះឡើយ សេចក្ដីពិត ដែលគេមិនយកចិត្តទុកដាក់ក្នុងរឿងសាសនាឬធម៌អាថ៌ អាចទាក់ ទងមកពីគេមិនមានសេចក្ដីចេះដឹងគ្រប់គ្រាន់ ល្មមនឹងស្រាវជ្រាវ រាវរកសេចក្ដីពិតចាកព្រះសាសនានេះក៏អាចថាបាន ។ តាមពិត

ព្រះពុទ្ធសាសនា គឺជាផែនទីដ៏ជាក់លាក់ សម្រាប់នាំសត្វលោកដែលដើរតាម ឱ្យទៅដល់គោលដៅយ៉ាងគួរអោយពេញចិត្ត ឬ ថាជាមធ្យោបាយដ៏សមស្របសម្រាប់ចោទ និងដោះស្រាយនូវរាល់បញ្ហាជីវិតរបស់មនុស្សគ្រប់វ័យ គ្រប់ប្រភេទមិនថាអតីតៈបច្ចុប្បន្ន ឬ អនាគត មិនរើសសម័យកាល នរណាប្រតិបត្តិតាមក្នុងវេលាណា ក៏អោយផលក្នុងវេលានោះ មិនបាច់រង់ចាំជាតិមុខរឺជាតិក្រោយឡើយ ប្រៀបបីដូចជាទឹកស្រះថ្លាដ៏ត្រជាក់ ឱ្យតែយើងដងយកមកចាក់លើកាយ ខណៈណា ក៏ផ្តល់ឱ្យនូវភាពត្រជាក់ខណៈនោះភ្លាម។ ព្រះធម៌ឬព្រះពុទ្ធសាសនា ជាការចោទនិងដោះស្រាយនូវបញ្ហាជីវិត ដូច្នេះព្រះធម៌គឺជាគោលនៃជីវិត យ៉ាងណាមិញ? យ៉ាងនេះគឺៈ

បើជីវិតប្រាសចាកធម៌ដូចជា **សតិ** ជីវិតនោះក៏នឹងវិកលចរិត ប្រាសចាកប្រយោជន៍, បើប្រាសចាកធម៌ **ហិរិ-ឱត្តប្បៈ** ក៏ជាជីវិតខ្មៅសៅហ្មង ពុករលួយ ច្រើនប្រកបដោយទោស, បើប្រាសចាកធម៌ **បញ្ញា** ក៏ជាជីវិតងងឹតងងល់ មិនស្គាល់ច្បាស់នូវអ្វីជាប្រយោជន៍ និង មិនមែនជាប្រយោជន៍ បើប្រាសចាកធម៌ **វិរិយៈ** គឺសេចក្តីព្យាយាម ក៏ជាជីវិតអន់ថយក្រោយ គ្មានជំហានឈានទៅរកសេចក្តីចំរើនថ្កុំថ្កើងរុងរឿង មិនអាចដកខ្លួនចាករណ្តៅទុក្ខបាន,

បើប្រាសចាកធម៌ **មេត្តា-ករុណា** ក៏ជាជីវិតសាហាវយង់ឃ្នង ឃោរឃៅក្រៅមនុស្សធម៌ ។ល។

សេចក្តីដូចរៀងមកខាងលើ ក៏សបញ្ជាក់អោយឃើញថា ធម៌មាននៅក្នុងជីវិតនេះឯង ហើយជីវិតពិតជាត្រូវការធម៌ល្អៗ សម្រាប់ដាស់តឿនក្រើនរំលឹកស្មារតីឱ្យបានជារឿយៗ ។ ការដែលអ្នកខ្លះពោលដៀលត្មះធម៌ ឬពុទ្ធសាសនាថាយ៉ាងនេះរឺយ៉ាងនោះ ព្រោះគេមើលពុទ្ធសាសនាតែតាមសភាព សើៗខាងក្រៅ ហើយគេមិនបានសិក្សា មិនបានពិចារណាឱ្យស្គាល់ច្បាស់តែប៉ុណ្ណោះ តែបើគេស្គាល់ច្បាស់ យល់ច្បាស់នូវព្រះពុទ្ធសាសនាតាមសេចក្តីដែលពិត បានក្រេបរសជាតិនៃព្រះធម៌ឱ្យបានជារឿយៗហើយនោះ គេមុខជារីករាយស្រលាញ់ព្រះធម៌ស្មើដោយជីវិតពិតប្រាកដមិនខាន ។

| | |
|---|---|
| ជីវិតគឺជាការដើរផ្លូវឆ្ងាយ | ឯរូបរាងកាយជាសាលាសំណាក់ |
| ផ្លូវឆ្ងាយគឺជាឈ្មោះនៃវដ្ដៈ | ឥតធម៌ពឹងពាក់ជាក់ជាអន្តរាយ ។ |

**មេត្តា-ករុណា**

## សីលធម៌ឬសីល៥

ពាក្យថា **សីលធម៌** មកពី **សីល+ធម៌** បានទៅជា **សីលធម៌** ។ **សីល** គឺជាចេតនាដែល វៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយ វាចា, ការកាន់ចរិយាល្អ, ការសង្រួមអង្គនៃ ចរិយា, មាយាទល្អ, សេចក្ដីល្អ, អំពើល្អ, ។ល ។ ឯពាក្យថា **ធម៌** ក្នុងទីនេះ គឺសំដៅយកតែធម៌ល្អដែលជាលទ្ធផលនៃការប្រព្រឹត្តល្អគឺ **សីល** នោះឯង រួមពាក្យទាំងពីរបញ្ចូលគ្នាបានជា **សីលធម៌** បានសេចក្ដីថា ដំបូន្មានដែលនាំអោយវៀរចាកអំពើអាក្រក់ ហើយអោយប្រព្រឹត្តតែអំពើល្អ ដូច្នេះ **សីល** និង **ធម៌** គឺជាគូនឹងគ្នា មិនអាចបែកគ្នាបានឡើយ អ្នកណាគ្មានសីល អ្នកនោះគ្មានធម៌, អ្នកណាមានសីលអ្នកនោះមានឈ្មោះថា ជាអ្នករស់នៅប្រកបដោយធម៌ ឬ សីលធម៌ ព្រោះអ្នកមានសីលគឺជាអ្នកសម្បូណ៌ទៅដោយសេចក្ដីសុខស្ងប់ សម្រាប់ខ្លួនឯងផង និងអ្នកដ៏ទៃផង ។ តើពាក្យថា អ្នកមានសីល មានឈ្មោះថាមានធម៌ឬសីលធម៌នោះមានសេចក្ដីយ៉ាងណា ? សេចក្ដីនោះ យ៉ាងនេះគឺៈ

ទី១- មិនសម្លាប់សត្វ នាំអោយមានធម៌ **មេត្តា**

ទី២- មិនលួចទ្រព្យគេ នាំអោយមានធមិ **សម្មាអាជីវៈ**

ទី៣- មិនប្រព្រឹត្តខុសក្នុងកាម នាំអោយមានធមិ **សទារសន្តោសៈ**

ទី៤- មិននិយាយកុហក នាំអោយមានធមិ **សច្ចៈ**

ទី៥- មិនផឹកទឹកស្រវឹង នាំអោយមានធមិ **សតិ-សម្បជញ្ញៈ**

ពុទ្ធសាសនិកជនដែលស្ម័គ្រចិត្តរក្សាសីល៥ជាដើម ពុំមែនជាទម្លាប់ដែលធ្វើត។គ្នា ឬគ្រាន់តែធ្វើឱ្យល្អមើលនោះទេ តែជាការប្រព្រឹត្តដើម្បីអប់រំចិត្ត ប្រក់ព្រំឱ្យបានជាម្លប់ដ៏ត្រជាក់របស់ចិត្ត ជាគ្រឿងអលង្ការរបស់ចិត្ត ធ្វើអោយចិត្តមានសេចក្តីសុខដ៏ត្រជាក់ព្រោះការរក្សាសីលនេះឯង ។ អ្នករក្សាសីលមិនត្រឹមតែនាំមកនូវសេចក្តីសុខសម្រាប់ខ្លួនឯងប៉ុណ្ណោះទេ តែជាការនាំមកនូវសេចក្តីសុខដល់ក្រុមគ្រួសារ បងប្អូនសាច់ញាតិ សង្គមជាតិ និងលោកធាតុទាំងមូល ព្រោះអ្នករក្សាសីលជាអ្នក សម្បូរណ៍ទៅដោយសេចក្តីសុខ ។ ដើម្បីអោយដឹងថា តើគុណជាតិត្រឹមតែសីល៥ អាចជាហេតុនាំអោយកើតធមិល្អ។សម្រាប់មនុស្សជាតិយ៉ាងណានោះ ខ្ញុំសូមអញ្ជើញលោកអ្នកអានតាមដាននូវ មាតិកាសីលម្តងមួយ។ដោយមានសេចក្តីសង្ខេបដូចតទៅៈ

## សីលទី ១ (មិនសម្លាប់សត្វ)

ជីវិតគឺជាវត្ថុបំណងដ៏សំខាន់បំផុតសម្រាប់សត្វលោកគ្រប់ៗរូប ទោះជាសត្វនោះកើតមកមាន លក្ខណៈល្អក្តី អាក្រក់ក្តី ពាលក្តី បណ្ឌិតក្តី ក្មេងក្តី ចាស់ក្តី ជាអ្នកស្តុកស្តម្ភក្តី កំសត់ទុគ៌តក្តី ជាអ្នកមានអវយវៈគ្រប់គ្រាន់ក្តី ឬក៏ដល់នូវសភាពជាអ្នកពិការយ៉ាងណាក្តី ក៏នៅតែត្រូវការជីវិត ព្រោះជីវិតគឺជាវត្ថុដ៏សំខាន់មានតែមួយគត់សម្រាប់សត្វលោកគ្រប់ៗរូប ។ សត្វលោកគ្រប់ៗរូប គេស្រលាញ់ជីវិតរបស់គេណាស់ គ្មានអ្នកណាចង់ស្លាប់ទេ គេសុខចិត្តលះបង់ទ្រព្យសម្បត្តិដើម្បីការពារអវយវៈ គេលះបង់អវយវៈដើម្បីការពារជីវិត នៅពេលដែលការពារជីវិតមិនបាន គេសែនសោកស្តាយនិងតក់ស្លុតយ៉ាងខ្លាំងក្រៃលែង ដូច្នេះជីវិតជារបស់ប្រសើរកាត់ថ្លៃពុំបាន គ្មានទីផ្សារដាក់លក់ទេ មហាសេដ្ឋី មហាមូលធន ក៏មិនអាចយកប្រាក់ទិញបានដែរ បើអាចទិញបានគេមិនព្រមស្លាប់ងាយៗនោះទេ ។

អ្នកដែលត្រូវគេសម្លាប់ រមែងព្រាត់ប្រាសចោលរបស់ជាទីស្រលាញ់ ជាទីគាប់ចិត្ត ស្លាប់ទៅ ទាំងសេចក្តីភិតភ័យតក់ស្លុត

ចំណែកញាតិមិត្ត បងប្អូនសាច់សាលោហិតជិតស្និទ្ធរបស់គេ ជ្រួលច្របល់ យំយែកទួញសោកបោកប្រាណ ព្រោះហេតុតែបុគ្គលជាទីស្រលាញ់ ត្រូវបាត់បង់ជីវិតដោយសារការសម្លាប់នោះ ដូច្នេះយើងមានឈ្មោះថាជាមនុស្សម្នាក់ ត្រូវតែមានប្រាជ្ញាស្មារតីឧស្សាហ៍ពិចារណាឱ្យបានជារឿយៗថា បើយើងស្រលាញ់ជីវិតរបស់យើងយ៉ាងណា អ្នកដ៏ទៃគេក៏ស្រលាញ់ជីវិតរបស់គេ យ៉ាងនោះដែរ បើយើងចង់រស់ នោះអ្នកដ៏ទៃគេក៏ចង់រស់ដូចយើងដែរ... កាលបើយើងឧស្សាហ៍ពិចារណាយ៉ាងនេះអោយបានជារឿយៗ នោះយើងនឹងក្លាយទៅជាមនុស្សមិនមានចិត្តចង្អៀតចង្អល់ ជាចិត្តធំទូលាយមានសេចក្ដីអនុគ្រោះ ឱ្យនូវអភ័យដល់សត្វទាំងអស់ក្នុងលោក ដូចជា ព្រៃធំតែងផ្ដល់ នូវភាពកក់ក្ដៅដល់ម្រឹគីម្រឹគា , ដូចជាអាកាសវេហាដ៏ធំទូលាយតែងផ្ដល់នូវការសប្បាយដល់បក្សី សត្វ , ឬដូចជា . មហាសមុទ្រតែងផ្ដល់ជម្រកដ៏សុខសាន្តដល់មច្ឆាទាំងឡាយ យើងត្រូវតែជាមនុស្សមានចិត្តទូលាយដូចជាផែនដី ត្រូវឧស្សាហ៍ស្ដាប់នូវធម៌របស់សប្បុរស អប់រំចិត្តអោយបានល្អ រហូតទាល់តែចិត្តយើង បានជ្រកក្រោមម្លប់ដ៏ត្រជាក់នៃព្រហ្មវិហារធម៌គឺ

មេត្តា ។

ការដែលយើងកំពុងរស់នៅសព្វថ្ងៃនេះ ពុំមែនពឹងពាក់ចំពោះតែទ្រព្យសម្បត្តិ កិត្តិយសប៉ុណ្ណោះទេ យើងពិតជាត្រូវការធម៌មេត្តាការរាប់អាន ការអោយអភ័យពីអ្នកដទៃ ជាចំបាច់ណាស់ ព្រោះថាបើអ្នកដទៃគ្រប់ៗរូបប្រាសចាកធម៌មេត្តា ក្លាយជាមនុស្សឃោរឃៅគ្មានត្រាប្រណីហើយ នោះយើងក៏មិនអាចរស់នៅបានសុខឡើយ សូមឱ្យមនុស្សគ្រប់ៗគ្នាចងចាំថា ដែលយើងនៅរស់ព្រោះអ្នកដទៃគេមិនសម្លាប់យើង តើហេតុអ្វីបានជាគេមិនសម្លាប់យើង ? គឺបានមកអំពីការដែល គេតាំងចិត្តថា អាត្មាអញមិនបៀតបៀន មិនសម្លាប់សត្វដទៃនោះឯង ដូច្នេះជីវិតពិតជាត្រូវការមេត្តាធម៌ បើប្រាសចាកមេត្តាធម៌ហើយ សកលលោកនេះនឹងក្លាយទៅជាថ្លុកឈាម ព្រោះតែការ កាប់សម្លាប់គ្នាពុំខាន។

| | |
|---|---|
| ដឹងថាជីវិតពិតមានតំលៃ | គួរខំកែខៃរួសរាន់សាងល្អ |
| លះក្តីប្រមាទសង្វាតធម៌ស | ធ្វើជាមនុស្សល្អរបស់សង្គម។ |

សាន-សុខា

## សីលទី ២ (មិនលួចទ្រព្យគេ)

ក្នុងសីលទី២នេះ ទ្រង់ហាមមិនអោយលួចទ្រព្យអ្នកដទៃ ហើយអោយប្រកបមុខរបរចិញ្ចឹម ជីវិតដោយសុចរិតត្រឹមត្រូវតាមគន្លងធម៌ ដែលហៅថា **សម្មាអាជីវៈ** ។

អ្នកខ្លះដែលមិនបានសិក្សាឱ្យបានដល់ជម្រៅនៃព្រះពុទ្ធ-សាសនា មានការចោទប្រកាន់ថា ព្រះពុទ្ធសាសនានិយាយតែពីរឿងបុណ្យបាបៗ ម្ល៉ោះហើយធ្វើអោយអ្នកគោរពតាមមានសភាពក្រលំបាក គេយល់ថា ការប្រកបមុខរបរប្រចាំជីវិត ទាល់តែចេះបន្លំបោកប្រាស់ កុហក និយាយបញ្ឆោត ឬ ថាចេះរបៀបកោរមិនដាក់ទឹកនោះ ទើបបានទទួលជ័យជំនះក្នុងការប្រកបមុខរបនោះ សួរថាគួរបើសប្បាយណាស់ទៅឬ ជាមួយទ្រព្យសម្បត្តិដែលបានមកដោយអំពើទុច្ចរិតនោះ? មនុស្សម្នាក់ៗគ្មាន ស្រលាញ់អ្វីឱ្យខ្លាំងជាងស្រលាញ់ខ្លួនឡើយ ចុះបើដឹងថាខ្លួនក្លាយជាចោរ ឬមនុស្សទុរជនហើយនោះ តើមានអ្វីនៅល្អសម្រាប់ខ្លួនទៀតទៅ! ការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ គឺដើម្បីដោះស្រាយបញ្ហាជីវិតរបស់សត្វលោកហ្នឹងឯង ប៉ុន្តែសត្វលោកភាគច្រើនចេះតែមើលរំលង

ឃើញលាមកថាជា ផ្កា ឃើញរបស់ល្អថាគ្មានតំលៃ ខំបង្កើតសេចក្តីលោភលន់ឱ្យកាន់តែច្រើនឡើងៗ រហូតទាល់តែភ្លេចតួនាទីរបស់ខ្លួនថាជាមនុស្ស ។

ព្រះពុទ្ធសាសនាបានបង្រៀនមនុស្សឱ្យចេះដឹងពីប្រយោជន៍ ៣យ៉ាងគឺៈ

១-ប្រយោជន៍បច្ចុប្បន្ន

២-ប្រយោជន៍លោកខាងមុខ

៣-ប្រយោជន៍ក្នុងព្រះនិព្វាន

តែក្នុងទីនេះ ខ្ញុំសូមបើករង្វង់ក្រចកបន្តិចដើម្បីលើកយកធម៌ខ្លះៗ ដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ និងសេដ្ឋកិច្ចសង្គម ដែលជាប្រយោជន៍អាចមើលឃើញផ្ទាល់នឹងភ្នែកដូចតទៅៈ

**ក-ទិដ្ឋធម្មិកត្ថប្រយោជន៍៤យ៉ាង**( ប្រយោជន៍បច្ចុប្បន្ន )

១-ព្យាយាមស្វែងរកទ្រព្យសម្បត្តិ

២-ចេះថែរក្សាទ្រព្យដែលរកបានមកហើយ

៣-សេពគប់រកមិត្តល្អត្រឹមត្រូវ

៤-ចេះចាយវាយទ្រព្យសម្បត្តិឱ្យសមតាមឋានៈរបស់ខ្លួន។

១-កិច្ចការប្រឹងប្រែងរកទ្រព្យសម្បត្តិ គឺជាកាតព្វកិច្ចដ៏សំខាន់សម្រាប់មនុស្សម្នាក់ៗ ទ្រព្យសម្បត្តិមិនអាចកើតមានដល់មនុស្សខ្ជិលច្រអូសបានឡើយ ដូចបុរាណបានពោលថា "ចេះពីរៀន មានពីរក" ។

២-ការថែរក្សាទ្រព្យដែលរកបានមកឱ្យគង់វង្សល្អ បានដល់ការចេះសន្សំសំចៃទ្រព្យទុក អោយផុតពីសេចក្តីអន្តរាយផ្សេងៗ ហើយនឹងចេះកែខៃរកផលកំរៃអំពីទ្រព្យនោះទៀតផង ។ ក្នុងប្រទេសនីមួយៗ គេតែងមានកន្លែងផ្ញើប្រាក់ ដែលហៅថា **ធនាគារ** ដើម្បីអោយប្រជាជនចេះ សន្សំទ្រព្យសម្បត្តិ ហើយបានថ្លៃការអំពីប្រាក់ទាំងនោះថែមទៀត ។

៣-ការជ្រើសរើសមិត្តភ័ក្តិ គឺជាការជ្រើសរើសផ្លូវដើរសម្រាប់ជីវិត បើសេពគប់មិត្តអា ក្រក់រមែងនាំមកនូវសេចក្តីវិនាសគ្រប់ច្រកល្ហក, បើសេពគប់មិត្តល្អ នឹងមានសេចក្តីសុខចំរើនកើនប្រយោជន៍ជារឿយៗ ព្រោះមិត្តល្អគេអាចជួយពន្យល់វិធីស្វែងរកសេចក្តីសុខចំរើន ទាំងផ្នែកទ្រព្យសម្បត្តិ ទាំងផ្នែកគំនិតប្រាជ្ញាស្មារតី គេស្ទាត់ជំនាញក្នុងកិច្ចការណា គេនឹងជួយពន្យល់មិត្តក្នុង

កិច្ចការនោះមិនខាន ។ មិត្តអាក្រក់ប្រៀបដូចលាមក ឯមិត្តល្អប្រៀបបីដូចជាកំរងផ្កាមានក្លិនក្រអូប តើយើង គួររើសយកលាមកឬក៏ផ្កា ?

៤-ការចេះចាយវាយ ឱ្យសមនឹងឋានៈរបស់ខ្លួន បានសេចក្តីថា ការចាយវាយមិនអោយ លើសចំនួនទ្រព្យដែលមាន បើរកបានតិចចាយតាមតិច បើរកបានច្រើនកុំភ្លើតភ្លើនចាយទាល់តែអស់ ត្រូវវៀរចាកការចំណាយណាដែលគ្មានការចាំបាច់ឬគ្មានប្រយោជន៏ ត្រូវសំចៃទុកខ្លះសំរាប់ពេល ណាដែលរកទ្រព្យមិនបាន ឬមានគ្រោះថ្នាក់ផ្សេងៗមានជំងឺតម្កាត់ជាដើម ។

## ខ- លក្ខណៈអ្នកធ្វើជំនួញ៣យ៉ាងគឺ

១- **បញ្ញាចក្ខុ** ជាអ្នកមានបញ្ញា

២- **វិរិយារម្ភៈ** ជាអ្នកប្រារព្ធសេចក្តីព្យាយាម

៣- **សនាថោ** ជាអ្នកមានទីពឹងច្រើន

១-បញ្ញាចក្ខុ ជាអ្នកមានបញ្ញា គឺឆ្លាតក្នុងការលក់ចេញទិញចូល ដឹងថាធ្វើយ៉ាងណាខាត និងធ្វើយ៉ាងណាអោយចំណេញ, ស្គាល់កាល, ស្គាល់រដូវនៃមុខរបរនីមួយៗ, ស្គាល់ទីផ្សារសម្រាប់

លក់ ដូចជាថា កន្លែងណាលក់បានថ្លៃ កន្លែងណាលក់បានថោក, ស្គាល់សេចក្ដីត្រូវការរបស់មនុស្សក្នុងទី នោះៗគេត្រូវការទំនិញណា ត្រូវយកទំនិញនោះទៅលក់ តាមសេចក្ដីត្រូវការរបស់គេ... ដូច្នេះជាដើម ។

២-វីរិយារម្ភៈ ប្រារព្ធសេចក្ដីព្យាយាម គឺខិតខំសង្វាតធ្វើកិច្ចការដែលខ្លួនកំពុងធ្វើនោះ មិនខ្ជិលច្រអូស មិនបង្អង់ឱ្យហួសពេលវេលានៃមុខរបរនិងសេចក្ដីត្រូវការរបស់អ្នកទិញ ។

៣-សនាថោ ជាអ្នកមានទីពឹងច្រើន គឺប៉ិនប្រសប់ក្នុងការទាក់ទងមនុស្សបានច្រើន ទៅទីណាៗតែងមានគេរាប់អាន មានគេស្រលាញ់ ចេះធ្វើខ្លួនឱ្យគេស្រលាញ់រាប់អាន និងជាទីទុកចិត្តរបស់អ្នកដទៃ ។

លោកអ្នកអានទាំងឡាយ! តើមានកន្លែងណាដែលព្រះ-សម្មាសម្ពុទ្ធបង្រៀនអោយមនុស្សក្រ ឬទន់ខ្សោយស្មារតីដែររឺទេ? អ្នកដែលចោទព្រះពុទ្ធសាសនាដោយប្រការផ្សេងៗ ប្រៀបបីដូចជាមនុស្សខ្វាក់ ហើយខំស្រែកថាលោកនេះងងឹតណាស់ លោកនេះគ្មានពន្លឺទេ ព្រោះគេគ្មានភ្នែកគឺបញ្ញា ដើម្បីសិក្សាស្រាវជ្រាវនូវព្រះពុទ្ធ

វចនៈឱ្យបានច្បាស់លាស់ ។

ចេតនាវៀរចាកការលួចទ្រព្យអ្នកដទៃ គឺជាធម៌របស់មនុស្ស ព្រោះមនុស្សគ្រប់គ្នាចង់ឱ្យទ្រព្យសម្បត្តិគង់វង្ស បើមនុស្សគ្រប់គ្នាគោរពតាមសីលទី២នេះ គេនឹងមានឈ្មោះថាជាអ្នកមានធម៌ **សម្មាអាជីវៈ** កាលណាគេមានធម៌សម្មាអាជីវៈ នោះចោររមែងមិនមាន ។ អំពើឆក់ប្លន់ អំពើចាប់ជីវិតជាដើម ដែលនាំអោយមានភាពវឹកវរនៅក្នុងសង្គម មិនដែលកើតមកអំពីអ្នកមានសីលទេ គឺកើតមកអំពីតែមនុស្សគ្មានសីលតែប៉ុណ្ណោះ។ បើគ្រប់គ្នាមានសីលហើយ មនុស្សម្នាមិនចាំបាច់ ចាក់សោរទ្វារផ្ទះក៏បាន ព្រោះគ្មានចោរ ដូច្នេះសង្គមជាតិពិតជាមានសុខសន្តិភាពត្រូវការមនុស្សមានសីលខ្លាំងណាស់ ។

| |
|---|
| កើតមកជាមនុស្សត្រូវមានឈ្មោះល្អ ទោះមានឬក្រជារឿងធម្មតា<br>តែរឿងដែលធំគឺឬកចរិយា ជនជាតិខេមរាត្រូវតែថ្លៃថ្នូរ។ |

សាន.សុផា

## សីលទី ៣ (មិនប្រព្រឹត្តខុសក្នុងកាម)

ក្នុងសីលទី៣នេះ មានការទាក់ទងយ៉ាងសំខាន់ទៅនឹងសុភមង្គលក្នុងរង្វង់គ្រួសារ ។ មនុស្សភាគច្រើនយល់ឃើញថាស្នេហាឬការស្រលាញ់តែងនាំមកនូវសេចក្ដីសុខ តែក្នុងទស្សនៈនៃព្រះសម្មាសម្ពុទ្ធទ្រង់ឃើញថា ស្នេហាគឺជាបញ្ហាស្មុគស្មាញបំផុតសម្រាប់ជីវិត ។ គ្រួសារខ្លះមានការលះលែងគ្នា ដោយសាររឿងរ៉ាវសូម្បីបន្តិចបន្តួច ព្រោះហេតុអ្វី ? ព្រោះគេសំលឹងមើលគ្នានិងគ្នាទៅលើតែរូបសម្រស់ ដែលសម្រាប់បំពេញកាមតណ្ហារបស់គេរៀងៗខ្លួនតែប៉ុណ្ណោះ នៅពេលដែលរូបសម្រស់នៃដៃគូរបស់ខ្លួនមានការអន់ថយ គេក៏កើតសេចក្ដីនឿយណាយ ទន្ទឹមនឹងការនឿយណាយ គេក៏ចាប់ផ្ដើមត្រិះរិះរកដៃគូថ្មី ដើម្បីបំពេញចំណង់តណ្ហារបស់គេថែមទៀត ត្រង់បញ្ហានេះហើយ ដែលធ្វើអោយគូស្វាមីភរិយាអស់សេចក្ដីទុកចិត្តគ្នាទៅវិញទៅមក ហើយបញ្ហាផ្សេងៗ ក៏បានចាប់ផ្ដើមកើតជាបន្តបន្ទាប់ ដូចជាការនាំមេរោគអេដស៍ចូលផ្ទះជាដើម ។ តាមពិតមេរោគអេដស៍គ្មានអ្វីគួរឱ្យខ្លាចនោះទេ ព្រោះមេរោគអេដស៍មាននូវព្រំដែនកំនត់នៃការឆ្លងរបស់

វា តែមេរោគដែលគួរអោយខ្លាចហើយលំបាកក្នុងការព្យាបាលនោះ គឺរោគស្នេហា ព្រោះមេរោគស្នេហាគ្មានព្រំដែនពិតប្រាកដឡើយ ហើយវាជាបទដ្ឋាន ឬថាជាមាតាបិតាបង្កើតមេរោគអេដស៍ ។ គ្រាន់តែលោកអ្នកតាំងចិត្តថា អាត្មាអញមិនប្រព្រឹត្តខុសក្នុងកាម ហើយស្មោះត្រង់ចំពោះប្តីប្រពន្ធរបស់ខ្លួន នោះលោកអ្នកនឹងគេចផុតអំពីមេរោគអេដស៍ជាស្ថាពរ ។

សត្វតិរច្ឆាន ថ្វីបើមានកំណើតថោកទាបជាងមនុស្សក៏ពិតមែន ប៉ុន្តែក្នុងរឿងស្នេហារបស់វា មានកំណត់ពេលវេលាច្បាស់លាស់ មិនមែនចេះតែប្រព្រឹត្តផ្តេសផ្តាស់ខុសរដូវកាលឡើយ តែជាតិជាមនុស្ស បើគ្មានសេចក្តីស្មោះត្រង់ចំពោះប្តីប្រពន្ធរបស់ខ្លួនទេ ពិតជាអន់ជាងសត្វតិរច្ឆានយ៉ាងពិតប្រាកដ ។

បុរសខ្លះព្រោះតែបំពេញចំណង់តណ្ហារបស់ខ្លួន ហ៊ាន ប្រព្រឹត្តរំលោភបំពានទៅលើក្មេងស្រីតូចៗដែលមិនទាន់ដឹងក្តី យ៉ាង គួរអោយខ្លោចផ្សា ព្រោះអ្វី ? ព្រោះគេជាមនុស្សគ្មានសីល ។ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅឱ្យមនុស្សរក្សាសីលទី៣នេះ គឺបង្រៀន

ឱ្យមានសេចក្តីសន្តោសក្នុងរឿងកាមគុណ ឱ្យចេះត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន ហៅថា **សទារសន្តោសៈ** ។ ការត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន គឺជាការនាំមកនូវសេចក្តីសុខដល់គ្រួសាររបស់ខ្លួនផង ដល់គ្រួសារអ្នកដ៏ទៃផង ជាពិសេសអាចជួយជាកំលាំង ដល់ប្រទេសជាតិក្នុងការកាត់បន្ថយជំនួញផ្លូវភេទ ព្រោះអ្នករក្សាសីល បានវៀរចាកនូវការប្រព្រឹត្តអនាចារក្នុងរឿងកាមគុណ ។

| | | |
|---|---|---|
| អ្នកណាភក្តី | នឹងប្រពន្ធប្តី | ដែលបានរៀបការ |
| អ្នកនោះផុតព្រួយ | ក្នុងរឿងស្នេហា | អេដស៍កាចយ៉ាងណា |
| | ក៏ឆ្លងមិនបាន ។ | |

**សោង ស៊ុផា**

## សីលទី ៤ (មិននិយាយកុហក)

សីលទី៤នេះ ព្រះសម្មាសម្ពុទ្ធទ្រង់ហាមមិនឱ្យនិយាយកុហក ហើយឱ្យនិយាយតែពាក្យពិត មានប្រយោជន៏ ជាពាក្យពិរោះទន់ភ្លន់ សុភាពរាបសារ ដើម្បីអោយមនុស្សសាងប្រយោជន៏ដោយពាក្យសំដី និង សាងមិត្តភាពរវាងគ្នានិងគ្នា ព្រោះមានការជឿទុកចិត្តគ្នាទៅវិញទៅមក ។ ការមិននិយាយកុហក គឺជាការឱ្យនូវការពិតត្រង់ដល់អ្នកដ៏ទៃ ឱ្យនូវការមិនវង្វេងភាន់ច្រឡំ អ្នកដែលនិយាយពាក្យពិត គឺមានសំដីដូចជាផ្កាដែលមានក្លិនក្រអូបឱ្យតែរបូតចេញពីមាត់កាលណា អ្នកផងតែងរើសយកជាគ្រឿងប្រដាប់កាយ ដូចជាវាចារបស់ព្រះសម្មាសម្ពុទ្ធ ថ្វីបើពេលវេលាកន្លងទៅជាង ២៥៤០ឆ្នាំ ទៅហើយក៏ដោយ ក៏នៅតែមានក្លិនក្រអូបដដែល នៅតែមានមនុស្សម្នាជាច្រើនត្រូវការ ប្រាថ្នាចង់ស្តាប់ ព្រោះជាវាចាពិតឥតក្លែងក្លាយ ។

គួរហាត់និយាយតែវាចាល្អៗ មានប្រយោជន៏ដល់អ្នកស្តាប់ដែលជាវាចាសុភាសិត ព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀនឱ្យមនុស្សនិយាយនូវវាចាល្អ ៥ យ៉ាងគឺ:

១- ស្គាល់ពេលវេលាដែលគួរនិយាយ ។

២- និយាយពាក្យពិតតាមដែលដឹង ប៉ុន្តែត្រូវស្គាល់កាល ស្គាល់បុគ្គល ស្គាល់បរិសទ័ដែល ត្រូវនិយាយ ។

៣- និយាយពាក្យពិរោះ សុភាពរាបសារ មិនទ្រគោះបោះបោក ។

៤- និយាយពាក្យមានប្រយោជន៍ ធ្វើឱ្យអ្នកស្តាប់ស្ងប់រំងាប់ចិត្ត សូម្បីតែនិយាយបន្តិចបន្តួចក៏ដោយ ។

៥- និយាយប្រកបដោយចិត្តមេត្តាពិតៗ ចិត្តមានមេត្តាគឺជាចិត្តសប្បុរស ជាចិត្តមិនចង្អៀតចង្អល់ ជាចិត្តធំទូលាយ តែងអនុគ្រោះនូវប្រយោជន៍ដល់សត្វលោក ចង់ឱ្យសត្វលោកបាននូវសេចក្តីសុខ រួចផុតចាកក្តីទុក្ខទាំងពួង ។

សូមអោយមនុស្សគ្រប់គ្នា ធ្វើខ្លួនឯងអោយជាឧបមាថា អាត្មាអញមិនត្រូវការពាក្យកុហកអំ ពីអ្នកដ៏ទៃយ៉ាងណា អ្នកដ៏ទៃក៏មិនត្រូវការពាក្យកុហកពីអាត្មាអញយ៉ាងនោះដែរ ដូច្នេះអាត្មា

អញត្រូវតែជាអ្នកមានសីល គឺវៀរចាកការនិយាយកុហក ធ្វើឱ្យជាទីទុកចិត្តនៃអ្នកដទៃ ការនិយាយពាក្យពិត គឺជាការចូលរួមចំណែកក្នុងការកាត់បន្ថយនូវរឿងច្របូកច្របល់ក្នុងសង្គមជាតិ ធ្វើឱ្យជាតិរុងរឿង ក៏ដោយសារពលរដ្ឋមាននូវសច្ចៈធម៌ ។

| | |
|---|---|
| **សច្ចំ** វេ អមតា វាចា | ព្រះពុទ្ធត្រាស់ថាជាពាក្យមិនស្លាប់ |
| ព្រោះសច្ចៈពិតមានឫទ្ធិចំណាប់ | អ្នកផងចង់ស្តាប់ហើយជឿទុកចិត្ត ។ |

សាន-សុខា

## សីលទី ៥ (មិនផឹកទឹកស្រវឹង)

មនុស្សឆ្កួតឬវិកលចរិត ព្រោះគេបាត់បង់សតិសម្បជញ្ញៈ ឯសុរាគឺជាគ្រឿងពង្វក់ស្មារតី ដូច្នេះទើបមនុស្សត្រូវវៀរចាកការផឹកសុរា ។ តាមទស្សនៈអ្នកញៀនសុរាខ្លះនិយាយថា ការផឹកសុរាបន្តិចបន្តួចដើម្បីអោយបាយឆ្ងាញ់មិនមានទោសទេ ទាល់តែផឹកច្រើនទើបមានទោស តែនៅក្នុងព្រះពុទ្ធសាសនាបានប្រដៅឱ្យមនុស្សវៀរចាកស្រឡះ សូម្បីបន្តិចបន្តួចក៏ដោយ ព្រោះសុរានេះ គឺជាប្រភពនៃសេចក្តីវិនាសច្រើនយ៉ាងដូចជា ÷

១- **សុរា** នាំឱ្យវិនាសទ្រព្យសម្បត្តិ, ជីវិតរបស់យើងម្នាក់ៗសុទ្ធតែត្រូវការអាហារដើម្បីបរិភោគ បើអត់អាហារនឹងត្រូវស្លាប់ ប៉ុន្តែសុរាបើមិនផឹកក៏មិនស្លាប់ ដូច្នេះអ្នកផឹកសុរា គឺជាអ្នកចាយវាយទ្រព្យសម្បត្តិខ្ជះខ្ជាយដោយគ្មានប្រយោជន៍ ។

២- **សុរា** នាំឱ្យកើតជម្លោះ, អ្នកផឹកស្រវឹងស្រាច្រើនតែមានសំដីធំហួសមាឌ ហួសឋានៈ របស់ខ្លួន មិនសូវកោតញញើតអ្នកណាឡើយ បើមានអ្នកណា

ធ្វើអោយទាស់ចិត្តបន្តិច ក៏បញ្ឆេះភ្លើងកំហឹងឱ្យប្រាកដឡើង ដូចជាភ្លើងឆេះចំបើង ហើយស្រែកជេរអ្នកដ៏ទៃ ដោយប្រការផ្សេងៗ ដែលជាហេតុនាំអោយមានវិវាទទាស់ទែងគ្នា ។

៣- **សុរា** នាំឱ្យកើតរោគទាំងឡាយ, សុរាដែលអ្នកប្រមឹកឱ្យតំលៃថាគួរអោយសប្បាយណាស់នោះតាមពិតគឺជាថ្នាំពិសដ៏ពន្លឹក សម្រាប់ធ្វើឱ្យរាងកាយចុះខ្សោយអន់ថយ ហើយនឹងបង្កឱ្យមានរោគផ្សេងៗដូចជា រោគឈឺក្រពះ, រោគស្រវាំងភ្នែក, រោគឈឺថ្លើម ជាពិសេសគឺរោគវិកលចរិតដែល ហៅថា (ឆ្កួតសុរា) ។

៤- **សុរា** នាំឱ្យខូចឈ្មោះ, អ្នកស្រវឹងស្រា តែងធ្វើចរិយាមារយាទមិនគួរអោយចូលចិត្តឡើយ ច្រើនធ្វើនូវការរំខានដល់អ្នកផ្ទះជិតខាង ដូចជាការរាំច្រៀងស្រែកឡូឡាខុស ពេលវេលាជាដើម ដូច្នោះឈ្មោះរបស់គេត្រូវបានអ្នកផងតិះដៀល ថាជាមនុស្ស

ប្រមឹក ។

៥- **ស្រា** នាំឱ្យមានការបង្ហាញកេរ្តិ៍ខ្មាស, តាមធម្មតា មនុស្សយើងមានការអៀនខ្មាសណាស់ ទៅណាមក ណាតែងស្លៀកពាក់យ៉ាងសមរម្យ លុះតែសុរាចូល មកពង្វក់ស្មារតី ក៏ក្លាយជាមនុស្សលែងចេះអៀន ខ្មាសមួយរំពេច ជួនកាលអាចហ៊ានបើកបង្ហាញកេរ្តិ៍ ខ្មាសក្នុងទីសាធារណៈក៏សឹងមាន ។

៦- **ស្រា** ធ្វើបញ្ញាឱ្យមានកំលាំងថយ, បញ្ញាគឺជាទ្រព្យ ដ៏វិសេសវិសាលសម្រាប់មនុស្សគ្រប់ៗគ្នា ប៉ុន្តែ ចំពោះមនុស្សប្រមឹក មិនអាចមានឱកាសដើម្បី បណ្តុះបញ្ញាឱ្យកាន់តែភ្លឺស្វាងឡើងបានទេ មានតែ បាត់បង់ប្រាជ្ញាស្មារតីបន្តិចម្តងៗជាដរាប ។

គ្រួសារខ្លះ ប្តីជាមនុស្សប្រមឹក ហើយវាយធ្វើបាបប្រពន្ធ កូនដែលបង្កើតឱ្យមានអំពើហិង្សាក្នុងគ្រួសារ មិនគោរពសិទ្ធិគ្នា ធ្វើឱ្យកូនខ្លះខូចចិត្តត្បិតខ្មាសអ្នកជិតខាង រហូតក្លាយខ្លួនជាក្មេង អនាថា ឥតទីពឹង គ្មានគោលដៅពិតប្រាកដ ព្រោះវិបត្តិឪពុក ម្តាយ

ដែលជាហេតុនាំអោយមានសភាពមិន សុខស្ងប់ដល់សង្គមជាតិទាំងមូល ។

សូមឱ្យមនុស្សគ្រប់គ្នាមានចេតនាវៀរចាកការផឹកទឹកស្រវឹង ហើយយកពេលវេលាដ៏មាន តម្លៃបំពេញកិច្ចការតាមតួនាទីប្រកបដោយសតិ និង សម្បជញ្ញៈ ព្រោះប្រទេសជាតិត្រូវការចាំបាច់ណាស់នូវមនុស្សដែលមានសតិ និង សម្បជញ្ញៈគ្រប់គ្រាន់ក្នុងកិច្ចបំពេញការងារតាមតួរនាទី ។

សរុបសេចក្ដីមក សីលទាំង៥ ដូចបានពោលមកហើយ គឺជាលក្ខណៈគ្រឹះ ឬថាជាគោលមូលដ្ឋានដំបូងបង្អស់ សម្រាប់អប់រំមនុស្សឱ្យមានសណ្ដាប់ធ្នាប់ល្អ ជាពលរដ្ឋល្អរបស់ជាតិ ។

ខ្ញុំសូមបញ្ចប់កូនសៀវភៅរបស់ខ្ញុំត្រឹមតែប៉ុណ្ណេះ ថ្ងៃក្រោយបើមានឱកាស ខ្ញុំនឹងព្យាយាម លើកយកធម៌ល្អៗ មករៀបរៀង ដើម្បីជាធម្មបណ្ណាការសម្រាប់លោកអ្នកអានជាបន្តទៀត តែសូមកុំភ្លេចឧទ្ទិសបុណ្យកុសលចែកឱ្យខ្ញុំផងណា ! ។

៙៚៙៚៙

# ឈ្មោះអ្នកអត់សីល

អ្នកសំលាប់សត្វ មាននាមប្រាកដ ជា**ឃាតករ**
ព្រោះតែងបៀតបៀន ឱ្យសត្វវឹកវរ ដោយខ្លួនឥតធម៌
មេត្តាប្រណី ។

អ្នកលួចទ្រព្យគេ បន្លំវៀចវេរ ដោយពាក្យសំដី
ឬមួយដោយកាយ គំនិតអប្រិយ អ្នកនោះឯងនៃ
ជា**ចោរ**ប្រាកដ ។

អ្នកខុសក្នុងកាម នឹងប្រាកដនាម ថា**អ្នកផិតក្បត់**
ប្តីប្រពន្ធខ្លួន ឥតក្តីទៀងទាត់ ព្រោះកាមសង្កត់
ឥតអោយអៀនខ្មាស ។

អ្នកពោលមិនពិត ច្រើនបង់គំនិត ព្រោះគិតមិនច្បាស់
ពោលតាមចំណង់ កិច្ចកុងក្រឡះ អ្នកផងស្គាល់ច្បាស់
ថា**ក្បត់សំដី** ។

អ្នកផឹកសុរា នឹងបាននាមថា **អ្នកអត់ស្មារតី**
យ៉ាងហោចអ្នកនុះ ត្រូវជនប្រុសស្រី គេឱ្យនាមថ្មី
ថា**អ្នកប្រមឹក** ។

ហេតុនេះមិត្តអើយ ចូរកុំព្រងើយ កុំធុញកុំស្ពឹក
ត្រូវមានសីលប្រាំ ប្រចាំល្ងាចព្រឹក កុំភ្លូកកុំភ្លឹក
តាមលោកខាងក្រៅ ។
ព្រោះសង្សារវដ្ត គ្មានដើមប្រាកដ ឥតមានគោលដៅ
ច្នេះត្រូវប្រព្រឹត្ត តាមប្រាជ្ញប្រដៅ នាំសត្វឆ្ពោះទៅ
ព្រះនិព្វានហោង ។

**ភិក្ខុវជិរប្បញ្ញោ សាន-សុជា**

# សីលប្រាំជាថ្នាំការពារអបាយ

ព្រះពុទ្ធទ្រង់ផ្តាំ   អោយជាប់**សីលប្រាំ**   ទើបបានរួចខ្លួន
ទោះដល់ទីណា   រក្សាខ្ជាប់ខ្ជួន   អបាយភូមិ៤
មិនបានមកជិត ។

ទីមួយ**បាណា**   មិនត្រូវប្រហារ   អោយសត្វភ័យភិត
សត្វតូចសត្វធំ   ស្រលាញ់ជីវិត   ដោយការប្រព្រឹត្ត
ឥតធមិមេត្តា ។

**(ពីរ)អទិន្នាទាន**   កុំឃើញគេមាន   បំពានទ្រព្យា
អោយខំអត់ធ្មត់   សង្កត់ចិន្តា   ទ្រព្យគេគ្រប់គ្នា
សុខជាព្រោះយើង ។

**បីកាមេ**   កុំគិតគ្នាន់គ្នេរ   ដូចគេរោលភ្លើង
ត្រូវចេះសន្តោស   កូនគេកូនយើង   ជួយលើកតំកើង
សុខទាំងអស់គ្នា ។

**បួនមុសាវាទ**   មិនត្រូវពោលឃ្លាត   ចាកពាក្យសច្ចា
សំដីមិនពិត   អសោចឥតសារ   អោយគេខ្លោចផ្សា
ដោយសារសំដី ។

ប្រាំទ្រង់ហាមថា **មិនអោយផឹកស្រា** បំផ្លាញស្មារតី
ចូលពោះកាលណា ក្លាហានសំដី ពោលពាក្យព្រៃផ្សៃ
គ្មានអ្វីពិរោះ ។

លោកថា**សីលប្រាំ** លេបជាប្រចាំ ថ្នាំការពារគ្រោះ
លំបាកទ្រាំមែន តែជួយរំដោះ អោយបានផុតជ្រោះ
គ្រោះចូលអបាយ ។

**ឧបាសក ចៅ កុសល**
**សិស្ស មណីរត្ន**